អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការផ្ញើប្រាក់ពីពលករកម្ពុជាធ្វើការនៅក្រៅប្រទេស ថយចុះ ១៧%
- ទុនវិនិយោគវិស័យសំណង់ ធ្លាក់ចុះជាង ៣២%
- រាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញក្របខ័ណ្ឌគោលនយោបាយថ្មី ចាប់យកឌីជីថលសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច
- សេដ្ឋកិច្ចរបស់ប្រទេសវៀតណាម នឹងមានកំណើនខ្លាំងឡើងវិញ ក្នុងឆ្នាំ២០២១ និង២០២២
- ការនាំចូលទំនិញរបស់ចិន ពីសហរដ្ឋអាមេរិក មានចំនួនទាបជាងមុន នៅក្នុងខែឧសភា ឆ្នាំ២០២១
- ធនាគារពិភពលោក បន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីន នៅក្នុងឆ្នាំ២០២១
- តម្លៃប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះ ខណៈដែលវិនិយោគិនរង់ចាំមើលទិន្នន័យអតិផរណារបស់អាមេរិក
- រដ្ឋមន្ត្រីរតនាគារសហរដ្ឋអាមេរិក មានប្រសាសន៍ថា អត្រាការប្រាក់ខ្ពស់ អាចនឹងផ្តល់ផលល្អសម្រាប់សហរដ្ឋអាមេរិក
- កំណើនអតិផរណារបស់រុស្ស៊ី អាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច(ធនាគារកណ្តាលព្រមាន)

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការផ្ញើប្រាក់របស់ពលករកម្ពុជាធ្វើការនៅក្រៅប្រទេស ថយចុះ១៧%



*ប្រភព៖ phnompenhpost.com, 2021. AFP*

យោងតាមរបាយការណ៍ពីធនាគារជាតិនៃកម្ពុជា(NBC) ការទទួលប្រាក់បញ្ញើពីបរទេស បានធ្លាក់ចុះប្រមាណ ១៧% ពី ១,៥ប៊ីលានដុល្លារអាមេរិក នាឆ្នាំ២០១៩ មកនៅត្រឹម ប្រមាណ ១,២ ប៊ីលានដុល្លារអាមេរិក កាលពីឆ្នាំ ២០២០ ដែលការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច និងការរឹតបន្តឹងការធ្វើដំណើរនៅតាមបណ្តាប្រទេសគោលដៅរបស់ពលករចំណាកស្រុក ដែលកម្ពុជាបញ្ជូនទៅបំពេញការងារ។

របាយការណ៍នោះក៏បានបង្ហាញថា ក្នុងចំណោមចំនួនទឹកប្រាក់សរុបផ្ញើពីបរទេសនោះគឺ ៧៣% មានប្រភពមកពីប្រទេសថៃ ហើយបានធ្លាក់ចុះចំនួន១១%, ពីប្រទេសកូរ៉េមានចំនួន១៦% បានធ្លាក់ចុះ ៣០%, ពីប្រទេសជប៉ុន ចំនួន ៦% បានធ្លាក់ចុះ ៤% និងពីប្រទេសម៉ាឡេស៊ី មាន ១,៤% ធ្លាក់ចុះ ៥១% ធៀបនឹងឆ្នាំ២០១៩។

របាយការណ៍នេះបានបន្តទៀតថា ចំនួនពលករចំណាកស្រុកកម្ពុជា បានធ្លាក់ចុះ៨% នៅត្រឹមចំនួន១,២ លាននាក់ ក្នុងឆ្នាំ២០២០ បើធៀបនឹងចំនួន ១,៣ លាននាក់ក្នុងឆ្នាំ២០១៩។ ការធ្លាក់ចុះនៃកម្លាំងពលកកម្មនេះ ដោយសារ ការរីករាលដាលនៃជំងឺកូវីដ ១៩ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សម្មភាពសេដ្ឋកិច្ច ជាពិសេសក្រុមហ៊ុនអាជីវកម្មជាច្រើន។ ពលករចំណាកស្រុកជាច្រើនរបស់ប្រទេសកម្ពុជា បានវិលត្រឡប់មកស្រុកវិញ និងមានពលករចំណាកស្រុកថ្មីចំនួនតិចតួចប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យធ្វើចំណាកស្រុក ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ ១៩ នេះ។

របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ (ILO) នៅក្នុងកំណត់ហេតុសង្ខេបប្រចាំត្រីមាសកម្មវិធីអាស៊ានស្ទីពីកម្ពុជា ចាប់ពីខែមករាដល់ខែមីនាឆ្នាំ ២០២១ បានបង្ហាញថា កម្ពុជា គឺជាប្រទេសប្រភពដើមដ៏សំខាន់មួយនៃពលករចំណាកស្រុក ដែលមានជាង ១ ១០០ ០០០ នាក់រស់នៅបរទេសកាលពីឆ្នាំ ២០២០។

របាយការណ៍នេះបង្ហាញទៀតថា ពលករភាគច្រើនស្វែងរកការងារនៅក្រៅប្រទេស ដោយសារតែកង្វះឱកាសការងារគ្រប់គ្រាន់ដែលអាចរកបាននៅក្នុងស្រុក និងភាពខុសគ្នានៃប្រាក់ឈ្នួលពលកម្មនៅក្រៅប្រទេស។

*ដោយ ឈន ហាំ*

*ប្រភព៖ ៖ phompenhpost.com ចេញផ្សាយថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២ ១*

## ទុនវិនិយោគវិស័យសំណង់នៅកម្ពុជា ធ្លាក់ចុះជាង ៣២%



*ប្រភព៖ postkhmer, 2021 រូបភាព៖ ហ៊ាន រង្សី*

យោងតាមធនាគារជាតិនៃកម្ពុជា(NBC) បានបង្ហាញថា ទុនវិនិយោគលើវិស័យសំណង់នៅកម្ពុជា ដែលធ្លាប់មានកំណើនខ្ពស់ ក្នុងរយៈពេលប៉ុន្មានឆ្នាំជាប់ៗគ្នានេះ បានធ្លាក់ចុះយ៉ាងគំហុកកាលពីឆ្នាំ២០២០ ដោយសារវិបត្តិសុខភាពសកល ដែលបណ្តាលពីការឆ្លងរាលដាលជំងឺកូវីដ១៩ ដោយតម្លៃទុនវិនិយោគក្នុងវិស័យសំណង់ ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អនុម័ត មានតម្លៃសរុប ៧,៨ប៊ីលានដុល្លារអាមេរិក ថយចុះជាង៣២% ធៀបនឹងឆ្នាំ ២០១៩ ដែលមានតម្លៃ ១១,៤ ប៊ីលាន ដុល្លារអាមេរិក។

ចំណែកក្រឡាផ្ទៃសំណង់បានធ្លាក់ចុះ ២៧% ស្មើនឹងជិត ១៧ លានម៉ែត្រការ៉េ។ ក្នុងនោះ ផ្ទៃក្រឡាគម្រោងអភិវឌ្ឍន៍លំនៅឋានមាន៤៦% អគារពាណិជ្ជកម្ម៣២% និងឧស្សាហកម្ម១៥%។ ម្យ៉ាងវិញទៀត លំហូរ FDI លើវិស័យសំណង់ និងអចលនទ្រព្យបានធ្លាក់ចុះ១១% (ស្មើនឹង ១៧% នៃ FDI សរុប)។ ដោយឡែកសម្រាប់ចំនួនគម្រោងដែលក្រសួងបានអនុម័ត ក្នុងឆ្នាំ២០២០ មានចំនួន ៤ ៨៤១ គម្រោងកើនឡើង ១%។

លោក ជីវ ស៊ីវផេង ប្រធានគ្រប់គ្រងទូទៅនៃសមាគមអ្នកសាងសង់កម្ពុជា បានឱ្យដឹងថា មូលហេតុចម្បងដែលធ្វើឱ្យទុនវិនិយោគវិស័យសំណង់ឆ្នាំ២០២០ ធ្លាក់ចុះ គឺ មកពីការរឹតត្បិតលើការធ្វើដំណើរឆ្លងប្រទេស ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ ១៩។ ការធ្លាក់ចុះវិស័យសំណង់អគារដែលវិនិយោគដោយជនបរទេស នឹងត្រូវបន្តយូរ ឬឆាប់អាស្រ័យទៅលើស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ លើសកលលោក។ ទោះជាយ៉ាងណា លោកកត់សម្គាល់ឃើញថា ការបញ្ចេញប្រាក់ពីសំណាក់វិនិយោគិនក្នុងស្រុក ក្នុងឆ្នាំ ២០២០ លើការវិនិយោគលើសំណង់លក្ខណៈផ្ទះល្វែង និងបុរី កំពុងមានចរន្តកើនឡើងគួរឱ្យកត់សម្គាល់។

អ្នកស្រី អាន សុធីតា នាយិកាគ្រប់គ្រងក្រុមហ៊ុនអចលនទ្រព្យ CBRE Cambodia បានបង្ហាញថា ទុនវិនិយោគវិស័យសំណង់នៅក្នុងឆ្នាំ២០២១ អាចនឹងធ្លាក់ចុះបន្ថែមទៀត ធៀបនឹងឆ្នាំ ២០២០។ ចំណែកឯវិស័យអចលនទ្រព្យក៏មិនទាន់មានសកម្មភាពល្អឡើងវិញដែរក្នុងឆ្នាំនេះ។ ម្យ៉ាងទៀត ចំនួនការដ្ឋានសាងសង់លំនៅឋានលក្ខណៈអគារខុនដូ និងបុរី ក៏ថយចុះផងដែរ។

របាយការណ៍ធនាគារជាតិនៃកម្ពុជា ក៏បានឱ្យដឹងថា ទន្ទឹមនឹងការធ្លាក់ចុះទុនវិនិយោគវិស័យសំណង់ ទីផ្សារនាំចូលស៊ីម៉ងត៍ និងដែក ក៏បានធ្លាក់ចុះព្រមគ្នាក្នុងអត្រា ៤៨% និង ៤៣% រៀងគ្នា ដែលការធ្លាក់ចុះនេះមកពីតម្រូវការចុះទាប ស្របពេលដែលសមត្ថភាពផលិតស៊ីម៉ង់ត៍ក្នុងស្រុកកំពុងកើនឡើង។ រីឯការនាំចូលគ្រឿងសំណង់ផ្សេងៗទៀត មានកំណើនជិត ៨%។

*ដោយ ឈន ហាំ*

*ប្រភព៖* postkhmer.com *ចេញផ្សាយថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០២១*

## រាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញក្របខ័ណ្ឌគោលនយោបាយថ្មី ចាប់យកឌីជីថលសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច




ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
*ប្រភព៖ postkhmer, 2021 រូបភាព៖ ហេង ជីវ័ន*

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវក្រុបខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ ដើម្បីកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មី បន្ទាប់ពីវិស័យឌីជីថលបានក្លាយជាវិស័យស្នូលក្នុងពេលវិបត្តិជំងឺឆ្លងរាតត្បាតកូវីដ ១៩។

កម្ពុជានឹងជំរុញវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ក្នុងសន្ទុះ និងល្បឿនថ្មី ដោយយកវិស័យឌីជីថលជាមូលដ្ឋាន។ នេះជាការចាប់យកកាលានុវត្តភាពថ្មីៗ និងជំរុញផលិតភាពឱ្យមានប្រសិទ្ធភាព និងភាពប្រកួតប្រជែងខ្ពស់។

ក្របខ័ណ្ឌគោលនយោបាយនេះ នឹងមានសក្តានុពលទៅលើសេដ្ឋកិច្ច រួមមាន៖ ការតភ្ជាប់ខ្សែសង្វាក់ផលិតកម្ម និងខ្សែសង្វាក់តម្លៃតំបន់ និងសកល ការជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច ការបង្កើតការងារជំនាញ និងការវិនិយោគ និងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផងដែរ។

ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងក្នុងឯកសារនោះថា ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាបានកំណត់យកនូវចក្ខុវិស័យ «កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលឱ្យរស់រវើក ដើម្បីរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម ផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី»។

ឯកឧត្តមបានឱ្យដឹងទៀតថា ចក្ខុវិស័យនេះត្រូវសម្រេចឱ្យបានក្នុងរយៈពេល១៥ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣៥ ហើយអនុលោមតាមគោលការណ៍ចំនួន៣ គឺ ការកសាងមូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល។

ឯកឧត្តមក៏បានថ្លែងបន្តទៀតថា ស្ថិតនៅក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ ១៩ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល កម្ពុជាឆ្នាំ២០២១-២០៣៥ នឹងក្លាយជាផ្នែកដ៏សំខាន់នៃក្របខ័ណ្ឌផែនការស្តារសេដ្ឋកិច្ចឡើងវិញ ក្រោយវិបត្តិជំងឺកូវីដ១៩ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការទាក់ទាញវិនិយោគក្នុងស្រុក និងពីបរទេស និងការជំរុញការបង្កើតធុរកិច្ចថ្មី។

លោក ប៊ិន សុជាតិ ទីប្រឹក្សាស្ថាបនិកនៃកម្មវិធីបច្ចេកវិទ្យាសុខាភិបាលឌីជីថល«ពេទ្យយើង» បានបញ្ជាក់ថា នេះជាយុទ្ធសាស្ត្រមួយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចឱ្យមានដំណើរស្ទុះឡើងវិញ សម្រាប់ជួយសង្គ្រោះវិបត្តិសេដ្ឋកិច្ច ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ ១៩។

លោក សុជាតិ បានបន្តឱ្យដឹងទៀតថា បើទោះក្នុងវិស័យបច្ចេកវិទ្យារបស់កម្ពុជា ហាក់យឺតជាងគេ ក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ាន ប៉ុន្តែលោកជឿថា នេះជាឱកាសរបស់កម្ពុជាក្នុងការពង្រឹងសមត្ថភាព ក្នុងការបង្កើនភាពច្នៃប្រឌិតផលិតបច្ចេកវិទ្យា ដើម្បីឱ្យសហគមន៍

សេដ្ឋកិច្ច ឬសហគមន៍អាជីវកម្មប្រើប្រាស់ អាចដំណើរការក្នុងសម័យបច្ចេកវិទ្យាតាមគន្លងថ្មីឱ្យទាន់គេ។

លោក ម៉ាក ចំរើន សហស្ថាបនិកផ្សារទំនើបអនឡាញ Smile Shop បានឱ្យដឹងថា នេះជាចំណុចចាប់ផ្តើមដ៏ល្អមួយ ព្រោះវានឹងជួយដល់ការស្តារសេដ្ឋកិច្ច បន្ទាប់ពីស្ថានភាពជំងឺកូវីដ ១៩ អាចគ្រប់គ្រងបាន។

លោកជឿថា ប្រទេសកម្ពុជា នឹងរីកចម្រើនលឿនក្នុងការប្រតិបត្តិពាណិជ្ជកម្មលើអាជីវកម្មបង្កើតថ្មីដែលទាក់ទងនឹងបច្ចេកវិទ្យា ភាពច្នៃប្រឌិត ប្រសិនបើរាជរដ្ឋាភិបាលមានការលើកលែងពន្ធដល់អ្នកក្នុងវិស័យឌីជីថល។

លោកបញ្ជាក់ថា អាជីវកម្មបង្កើតថ្មីមួយចំនួននៅពេលចុះបញ្ជី អាចប្រឈមនឹងការបង់ពន្ធ ឬក៏ការលើកលែងពន្ធអ្វីផ្សេងៗទៀតនៅមិនទូលំទូលាយ សម្រាប់អាជីវកម្មបង្កើតថ្មីនៅក្នុងស្រុក។ បើសិនជារាជរដ្ឋាភិបាល មានគោលនយោបាយលើកលែងពន្ធសម្រាប់អាជីវករសេដ្ឋកិច្ចឌីជីថល និង e-commerce ក្នុងរយៈពេល ៣ ទៅ ៥ ឆ្នាំ នឹងជំរុញឱ្យមានការវិនិយោគខ្លាំងលើវិស័យនេះ»។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃពុធ ទី០៩ ខែមិថុនា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ ពីឆ្នាំ ២០២០ ដល់ឆ្នាំ២០២២

សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ប្រមាណថាមានកំណើនអវិជ្ជមានក្នុងអត្រា -៣,១% ដោយសាររងនូវវិបត្តិនៃជំងឺកូវីដ-១៩ និងបានធ្វើឲ្យមានការធ្លាក់ចុះនៃវិស័យឧស្សាហកម្ម (-១,២%) និង វិស័យសេវាកម្ម (-៦,២%) ខណៈដែលវិស័យកសិកម្មមានកំណើនវិជ្ជមាន (០,៥%)។ ទោះបីជាយ៉ាងណា ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ កំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៤,០% និង ៥,៧% រៀងគ្នា ដោយសារការរំពឹងទុកនូវការងើបឡើងវិញក្នុងកម្រិតយឺតនៃតម្រូវការសកល ការបន្ធូរបន្ថយនូវការរឹតត្បិតការធ្វើដំណើរ និងការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី និងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលក្នុងការជំរុញកំណើន នេះបើយោងតាមសេចក្តីព្រាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា កាលពីខែមីនា ឆ្នាំ២០២១។

ទន្ទឹមនឹងនេះ វិស័យកសិកម្ម ត្រូវបានព្យាករណ៍ថានឹងមានកំណើន ១,៣% ក្នុងឆ្នាំ២០២១ និង ១,១% ក្នុងឆ្នាំ២០២២ ដោយសារកំណើនល្អប្រសើរឡើងវិញនៃអនុវិស័យដំណាំ(១,៦%) និងអនុវិស័យនេសាទ(១,៥%)។ ខណៈពេលដែលវិស័យឧស្សាហកម្ម ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៥,៩% ក្នុងឆ្នាំ២០២១ និង៨,២% នៅក្នុងឆ្នាំ២០២២ ដោយសារការរំពឹងទុកនូវការងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពផលិតកម្ម តម្រូវការសកល និងលំហូរទុនវិនិយោគ ដែលក្នុងនោះរួមមាន វិស័យកាត់ដេរ (៤,៦%) វិស័យសំណង់(២,៩%) និងវិស័យកម្មន្តសាល (១២,៥%)។ ជាមួយគ្នានេះ វិស័យសេវាកម្ម ក៏ត្រូវបានព្យាករណ៍ថានឹងមានកំណើន ៣,៤% ក្នុងឆ្នាំ២០២១ និង ៥,១% ក្នុងឆ្នាំ២០២២ ដោយសារការរំពឹងទុកភាពប្រសើរឡើងវិញយឺតនៃសកម្មភាពធ្វើដំណើរនិងលំហូរទុនវិនិយោគពីបរទេស ដែលនឹងជួយជំរុញដល់អនុវិស័យ

អចលនទ្រព្យ (២,៧%), សណ្ឋាគារ និងភោជនីយដ្ឋាន (០,៣%) និងអនុវិស័យដែលគាំទ្រដល់សកម្មភាពទេសចរណ៍ផ្សេងៗទៀត៕

*ដោយ វត្តា វង្សខ្មែរ:*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១*

## តារាងទី២៖ ការនាំចេញអង្ករបស់កម្ពុជា រយៈពេល៥ខែ ក្នុងឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងរយៈពេល ៥ខែនេះ កម្ពុជា បាននាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ សរុបចំនួន ២៣៣ពាន់តោន ដែលស្មើទៅនឹងទំហំទឹកប្រាក់ចំនួន ១៦៦,៨១លានដុល្លារអាមេរិក ក្នុងនោះ បរិមាណអង្ករសរុបជាង ១២០ពាន់តោន ឬ ជិត ៥២% ត្រូវបាននាំទៅកាន់ប្រទេសចិន រួមទាំង ហុងកុង និងម៉ាកាវ ដែលគិតជាទឹកប្រាក់ស្មើនឹង ៧៧,៥២លានដុល្លារអាមេរិក។

ទន្ទឹមនឹងនេះ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ការនាំចេញអង្ករ មានការធ្លាក់ចុះចំនួន ៣៤,៦% ស្មើនឹងចំនួនសរុប ៣៥៦ពាន់តោន ដែលការធ្លាក់ចុះនេះបណ្តាលមកពីវិបត្តិកូវីដ-១៩ ដែលប៉ះពាល់ដល់ចរន្តនៃលំហូរពាណិជ្ជកម្ម និងវិស័យផ្សេងៗដែលគាំទ្រដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ រួមមាន៖ កង្វះកុងតែន័រ និងការឡើងថ្លៃដឹកជញ្ជូនផ្លូវឆ្ងាយតាមសមុទ្រ ជាពិសេសទៅសហគមន៍អឺរ៉ុប។ នៅក្នុងរយៈពេល៥ខែ ដូចគ្នា នៅក្នុងឆ្នាំ២០២០ ទីផ្សារសហគមន៍អឺរ៉ុប មានចំណែកនៃការនាំចេញអង្ករសរុបរបស់កម្ពុជាជាង ៣៤% ដែលប្រហាក់ប្រហែលនឹងទីផ្សារចិន (៣៨%) ឬដែលគិតជាបរិមាណមានចំនួនជាង ១២០ពាន់តោន ខណៈពេលដែលក្នុងឆ្នាំ២០២១នេះ ការនាំចេញទៅកាន់ទីផ្សារសហគមន៍អឺរ៉ុបមានត្រឹមតែជិត៦០ពាន់តោន ឬជាង ២៥%នៃការនាំចេញសរុបប៉ុណ្ណោះ។ ក្រៅពីនេះ ការនាំចេញទៅប្រទេសផ្សេងៗ ដូចជាសហរដ្ឋអាមេរិក ក៏បានធ្លាក់ចុះពីជាង ២ ០០០តោន មកត្រឹមជាង ២០០តោន ផងដែរ៕ *ដោយ វត្តា វង្សខ្មែរ:*

| ការនាំចេញអង្ករកម្ពុជារយៈពេល៥ខែ ឆ្នាំ២០២១ | | | |
|---|---|---|---|
| **ខែ** | **2020** | **2021** | **កំណើន** |
| **មករា** | 50.5 | 34.3 | -32.1% |
| **កុម្ភៈ** | 86.0 | 41.9 | -51.2% |
| **មីនា** | 94.4 | 77.5 | -18.0% |
| **មេសា** | 69.3 | 38.8 | -44.0% |
| **ឧសភា** | 55.8 | 40.5 | -27.4% |
| **សរុប** | 356.097 | 233.031 | -34.6% |

*ប្រភព៖ សហព័ន្ធស្រូវអង្ករកម្ពុជា ថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០២១*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## សេដ្ឋកិច្ចរបស់ប្រទេសវៀតណាម នឹងមានកំណើនខ្លាំងឡើងវិញ ក្នុងឆ្នាំ២០២១ និង២០២២

យោងតាមតារាងខាងក្រោម សេដ្ឋកិច្ចរបស់វៀតណាម មានកំណើនខ្ពស់នៅក្នុងឆ្នាំ២០១៩។ កំណើននេះគឺដោយសារតែមានតម្រូវការក្នុងស្រុកខ្លាំង ឧស្សាហកម្ម ផលិតកម្ម និងកែច្នៃ និងវិនិយោគផ្ទាល់ពីបរទេស (FDI) យ៉ាងច្រើន។

បើទោះបីមានការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រទេសវៀតណាមត្រូវបានគេព្យាករណ៍ថា ជាប្រទេសមានសេដ្ឋកិច្ចរីកលូតលាស់លឿន នៅអាស៊ី-អាគ្នេយ៍។ យោងតាមទិន្នន័យរបស់បច្ចុប្បន្នភាពទស្សនៈវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ចេញផ្សាយកាលពីខែមេសា ឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចរបស់វៀតណាមមានកម្រិតទាប នៅត្រឹម ២,៩% ក្នុងឆ្នាំ២០២០ ប៉ុន្តែនៅតែខ្ពស់ជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាអត្រាកំណើនខ្ពស់មួយនៅលើពិភពលោក។ កំណើននេះត្រូវបានគាំទ្រដោយសកម្មភាពក្នុងស្រុក និងការនាំចេញដ៏រឹងមាំ ជាពិសេសការនាំចេញគ្រឿងអេឡិចត្រូនិចដែលមានបច្ចេកវិទ្យាខ្ពស់ ពីព្រោះមនុស្សនៅជុំវិញពិភពលោកមានតម្រូវការសម្រាប់ធ្វើការងារពីចម្ងាយ។

យោងតាមរបាយការណ៍របស់បច្ចុប្បន្នភាពទស្សនៈវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ដដែល សេដ្ឋកិច្ចប្រទេសវៀតណាមត្រូវបានគេរំពឹងថានឹងកើនឡើង ៦,៧% ក្នុងឆ្នាំ២០២១ និង ៧,០% ក្នុងឆ្នាំ២០២២ ដែលជាកំណើនដ៏រឹងមាំ និងមានស្ថិរភាព ខណៈកំពុងទប់ទល់នឹងជំងឺរាតត្បាតកូវីដ-១៩។ គួរគត់សំគាល់ថា កំណើនសេដ្ឋកិច្ចរបស់វៀតណាម ត្រូវបានជំរុញដោយផលិតកម្មដែលផ្តោតលើការនាំចេញ ការបង្កើនការវិនិយោគ និងពង្រីកពាណិជ្ជកម្ម។ សន្ទុះកំណើនត្រូវបានគេរំពឹងថានឹងបន្តដោយសារការធ្វើកំណែទម្រង់ ដែលកំពុងបន្តដើម្បីកែលម្អបរិយាកាសធុរកិច្ច និងការចូលរួមរបស់វៀតណាមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន ដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចជឿនលឿនស្ទើរតែទាំងអស់៕

*ដោយ ជឹម ប៊ុនធឿន*




*ប្រភព៖* GDP Growth, Asian Development Outlook Update 2021 - April 2021

## ការនាំចូលទំនិញរបស់ចិនពីសហរដ្ឋអាមេរិក មានចំនួនទាបជាងមុន នៅក្នុងខែឧសភា ឆ្នាំ២០២១



*ប្រភព៖ CNBC ២០២១*

យោងតាមទិន្នន័យចេញផ្សាយដោយ អគ្គនាយកដ្ឋានរដ្ឋបាលគយនៃប្រទេសចិន កាលពីថ្ងៃចន្ទសប្តាហ៍នេះ បានបង្ហាញថា ការនាំចូលទំនិញពីសហរដ្ឋអាមេរិកមកកាន់ប្រទេសចិន មានតម្លៃជាទឹកប្រាក់ចំនួន ១៣,១១ពាន់លានដុល្លារអាមេរិក ក្នុងខែឧសភា ពោលគឺធ្លាក់ចុះពី ១៣,៩៤ពាន់លានដុល្លារអាមេរិក នៅក្នុងខែមេសា ឆ្នាំ ២០២១។ ទិន្នន័យនេះ បានបង្ហាញថាតួលេខក្នុងខែឧសភា ឆ្នាំ២០២១ គឺជាចំនួនទឹកប្រាក់ប្រចាំខែទាបបំផុតចាប់តាំងពីខែតុលា ឆ្នាំ២០២០។

ទោះជាយ៉ាងនេះក្តី ការនាំចូលសរុបរបស់ចិនពីបណ្តាប្រទេសផ្សេងៗទៀត បានកើនឡើងក្នុងល្បឿនលឿនបំផុតក្នុងរយៈពេល ១០ឆ្នាំនេះ ពោលគឺកើនឡើងដល់ ៥១,១% ខណៈដែលល្បឿននៃកំណើនការនាំចូលពីសហរដ្ឋអាមេរិក បានធ្លាក់ចុះមកនៅត្រឹម ៤១% ក្នុងខែឧសភា ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន និងធ្លាក់ចុះពី ៥២% នៅក្នុងខែមេសា ឆ្នាំ២០២១នេះ។

ចំណែកឯការនាំចេញទំនិញរបស់ចិន ទៅកាន់សហរដ្ឋអាមេរិក បានកើនឡើងដល់ ៤៤,៨៩ពាន់លានដុល្លារអាមេរិក ក្នុងខែឧសភា ពោលគឺកើនឡើងពី ៤២,០៥ពាន់លានដុល្លារ ក្នុងខែមេសា ឆ្នាំ២០២១។ ទោះយ៉ាងនេះក្តី ល្បឿននៃកំណើននេះ បានថយចុះមកនៅត្រឹម ២១% នៅខែឧសភា ធ្លាក់ចុះពី៣១% នៅក្នុងខែមេសា ឆ្នាំ២០២១។ ជារួម ការនាំចេញសរុបរបស់ចិន មានកំណើនយឺតជាងមុន ពោលគឺកើនឡើងត្រឹមតែ ២៧,៩% (គិតជាប្រាក់ដុល្លារអាមេរិក) ក្នុងខែឧសភា និង ៣២,៣% ក្នុងខែមេសា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ជាលទ្ធផល អតិរេកពាណិជ្ជកម្មរបស់ចិនជាមួយសហរដ្ឋអាមេរិក បានកើនឡើងដល់ ៣១,៧៨ពាន់លានដុល្លារអាមេរិក ក្នុងខែឧសភា ពោលគឺកើនឡើងពី ២៨,១១ពាន់លានដុល្លារអាមេរិក ក្នុងខែមេសា ឆ្នាំ២០២១។ ការកើនឡើងនេះនៅតែបន្ត បើទោះបីជាមានការខិតខំប្រឹងប្រែង ពីសំណាក់អតីតប្រធានាធិបតីសហរដ្ឋអាមេរិក លោក Donald Trump ក្នុងការកាត់បន្ថយអតិរេកនេះក៏ដោយ។

ទោះជាយ៉ាងណា សហរដ្ឋអាមេរិកនៅតែជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតរបស់ចិន ផ្អែកលើមូលដ្ឋានកម្រិតប្រទេស បើទោះបីជាមានភាពតានតឹងផ្នែកពាណិជ្ជកម្មក៏ដោយ៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០២១*

## ធនាគារពិភពលោក បន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីន នៅក្នុងឆ្នាំ២០២១



*ប្រភព៖ Reuters ២០២១*

ធនាគារពិភពលោក បានបន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសហ្វីលីពីន មកនៅត្រឹម ៤,៧% នៅក្នុងឆ្នាំ២០២១ ដោយសារសេដ្ឋកិច្ចបានធ្លាក់ចុះ

យ៉ាងខ្លាំងជាងការរំពឹងទុក នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះបើយោងតាមលោក Kevin Chua សេដ្ឋវិទូជាន់ខ្ពស់របស់ធនាគារពិភពលោក។

សេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីន ត្រូវបានព្យាករណ៍ជាលើកដំបូងដោយធនាគារពិភពលោក ថានឹងកើនក្នុងអត្រា ៥,៥% នៅឆ្នាំ២០២១ ធៀបជាមួយគោលដៅកំណើនរបស់រដ្ឋាភិបាលប្រទេសហ្វីលីពីន ស្ថិតក្នុងរង្វង់ពី ៦,០%ទៅ៧,០% នៅក្នុងឆ្នាំ២០២១។

ទន្ទឹមនឹងនេះ ធនាគារពិភពលោក ក៏បានបន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីន នៅក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ផងដែរ ជាមួយនឹងអត្រា ៥,៩% និង ៦,០% រៀងគ្នា ពោលគឺទាបជាងការព្យាករណ៍កាលពីខែមីនា ឆ្នាំ២០២១ ជាមួយនឹងអត្រា ៦,៣% និង ៦,២% រៀងគ្នា ។

លោក Kevin Chua បានដាក់ «ហានិភ័យនៃការធ្លាក់ចុះយ៉ាងខ្លាំងនៃសេដ្ឋកិច្ច» រួមទាំងការលេចឡើងជាថ្មីនៃការឆ្លងជំងឺកូវីដ-១៩បំលែងថ្មី និងការបន្តពេលការរឹតត្បិតការធ្វើដំណើរ ទៅក្នុងចក្ខុវិស័យរបស់ធនាគារពិភពលោក សម្រាប់ប្រទេសហ្វីលីពីន ។

លោក Kevin Chua បានបន្ថែមថា «គោលនយោបាយដ៏សំខាន់សម្រាប់ដោះស្រាយបញ្ហានេះគឺការគ្រប់គ្រងជំងឺកូវីដ-១៩ ការផ្តល់ការគាំពារសង្គម និងការប្រមូលផ្តុំការចូលរួមពីគ្រប់វិស័យ ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញឱ្យមានប្រសិទ្ធភាព»។

សូមបញ្ជាក់ដែរថា សេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីនបានធ្លាក់ចុះយ៉ាងគំហុកដល់ -៩,៦% កាលពីឆ្នាំ២០២០។ យោងតាមទិន្នន័យរបស់រដ្ឋាភិបាលបានបង្ហាញថា អត្រានិកម្មភាពបានកើនឡើងដល់ ៨,៧% នៅក្នុងខែមេសា ឆ្នាំ២០២១ ស្មើនឹងចំនួនអ្នកអត់ការងារធ្វើច្រើនជាង ៤លាននាក់ កើនពី ៧,១% នៅក្នុងខែមីនា ឆ្នាំ២០២១៕

*ដោយ ស៊ិន សុភាក់*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### តម្លៃប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះ ខណៈដែលវិនិយោគិនរង់ចាំមើលទិន្នន័យអតិផរណារបស់សហរដ្ឋអាមេរិក



*ប្រភព៖ Reuter, 2021 រូបភាព៖ REUTERS/Rick Wilking*

ប្រាក់ដុល្លារអាមេរិក បានធ្លាក់ចុះនៅថ្ងៃអង្គារសប្តាហ៍នេះដោយសារវិនិយោគិន បានរំពឹងនូវទិន្នន័យអតិផរណារបស់សហរដ្ឋអាមេរិក នាចុងសប្តាហ៍ខាងមុខ បន្ទាប់ពីទិន្នន័យនៃអត្រាការងារបានថយចុះលើសការរំពឹងទុក ដែលជាហេតុបណ្តាលឱ្យមានការរារាំងលើការពន្លឿន

នៃសកម្មភាពជំរុញសេដ្ឋកិច្ចរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក។

ប្រាក់អឺរ៉ូ ត្រូវបានជួញដូរក្នុងតម្លៃ ១,២១៩១៥ដុល្លារអាមេរិកក្នុងមួយអឺរ៉ូ កាលពីថ្ងៃសុក្រ កើនពី១,២១០៤ ដុល្លារអាមេរិកក្នុងមួយអឺរ៉ូ ដែលជាតម្លៃដ៏ទាបក្នុងរយៈពេល ៣សប្តាហ៍ ខណៈដែលប្រាក់ដុល្លារធៀបនឹងប្រាក់យ៉េន បានធ្លាក់ចុះដល់ ១០៩,២៦យ៉េនក្នុងមួយដុល្លារអាមេរិក បន្ទាប់ពីបានឡើងដល់ ១១០,៣២៥ យ៉េនក្នុងមួយដុល្លារអាមេរិក កាលពីចុងសប្តាហ៍មុន។

សន្ទស្សន៍ប្រាក់ដុល្លារអាមេរិក ធៀបនឹងកញ្ចប់រូបិយប័ណ្ណសំខាន់ៗចំនួន ៦ បានឈរនៅតម្លៃ ៩០,០២១ ដែលប្រហាក់ប្រហែលនឹង ៨៩,៥៣៣ ដែលជាកម្រិតទាបក្នុងរយៈពេល ៤ខែ កន្លះ គិតត្រឹមកាលពីចុងខែមុន។

ដោយឡែក ប្រាក់ផោនអង់គ្លេស ធៀបនឹងប្រាក់ដុល្លារអាមេរិក មានចំនួនស្មើនឹង ១,៤១៦៩ដុល្លារអាមេរិកក្នុងមួយផោន ខណៈដែលប្រាក់ដុល្លារអូស្ត្រាលី មិនមានការប្រែប្រួលដោយរក្សានូវកម្រិត០,៧៧ដុល្លារអូស្ត្រាលីក្នុងមួយដុល្លារអាមេរិក ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ ជាមួយនឹងភាពតឹងតែងផ្នែកពាណិជ្ជកម្មថ្មីៗនេះ ការប្រែប្រួលនៃរូបិយប័ណ្ណទាំងពីរខាងលើនេះ បានធ្លាក់ចុះដល់កម្រិតទាបបំផុតចាប់តាំងពីដើមឆ្នាំ២០២០ មុនពេលទីផ្សារត្រូវបានវាយលុកដោយជំងឺរាតត្បាតកូវីដ-១៩។

ចំណែកឯ ប្រាក់ដុល្លារអាមេរិកធៀបនឹងប្រាក់ប៉េសូម៉ិកស៊ិក (Mexican peso) មានតម្លៃ ១៩,៨៣២ប៉េសូក្នុងមួយដុល្លារអាមេរិក ដែលជាតម្លៃជិតដល់កម្រិតខ្ពស់បំផុតចាប់តាំងពីចុងខែមករា ឆ្នាំ២០២១ បន្ទាប់ពីការបោះឆ្នោតពាក់កណ្តាលអាណត្តិ បានបញ្ជាក់ថាគណបក្ស MORENA ជាគណបក្សដែលមានអំណាចបំផុតនៅក្នុងប្រទេស ប៉ុន្តែសំឡេងគាំទ្របានថយចុះ។

ដោយឡែក ប្រាក់ដុល្លារធៀបនឹងប្រាក់ប៉េរូ (Peruvian sol) បានធ្លាក់ចុះដល់តម្លៃទាបត្រឹម ៣,៩៣៦៧ប៉េរូក្នុងមួយដុល្លារអាមេរិក ខណៈដែលលោក Pedro Castillo អ្នកសង្គមនិយម បាននាំមុខគូប្រជែង ក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី។

រូបិយប័ណ្ណឌីជីថល (Cryptocurrencies ) ក៏មានការប្រែប្រួលតិចតួចផងដែរ។ រូបិយប័ណ្ណ Bitcoin ត្រូវបានជួញដូរក្នុងតម្លៃ ៣៣ ៥៦៤ដុល្លារអាមេរិកក្នុងមួយឯកតា ខណៈ រូបិយប័ណ្ណ Ether មានតម្លៃ ២ ៥៨១ដុល្លារអាមេរិកក្នុងមួយឯកត្តា។

យោងតាមលោក Shinichiro Kadota អ្នកយុទ្ធសាស្ត្ររូបិយប័ណ្ណជាន់ខ្ពស់នៅធនាគារ Barclays បានមានប្រសាសន៍ថា មូលហេតុមិនមែនដោយសារចំនួនការងារធ្លាក់ចុះនោះទេដែលធ្វើឱ្យប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ប៉ុន្តែដោយសារការរំពឹងទុកមុនជាច្រើនបានកើតឡើងមុនតួលេខត្រូវបានកំណត់ ដូចនេះហើយបានជាធ្វើឱ្យប្រាក់ដុល្លារអាមេរិកទទួលរងនូវការធ្លាក់ចុះតម្លៃ។

ទិន្នន័យអត្រាការងារកាលពីថ្ងៃសុក្រ របស់សហរដ្ឋអាមេរិក បានបង្ហាញថា ចំនួនការងារមិនមែនក្នុងវិស័យកសិកម្ម បានកើនឡើងដល់ចំនួន ៥៥៩ ០០០នៅក្នុងខែឧសភា ឆ្នាំ២០២១ ធ្លាក់ចុះចំនួន ៩០ ០០០ការងារ ទាបជាងការរំពឹងទុក។ ទិន្នន័យនេះ បានធ្វើឱ្យទិន្នផលមូលបត្របំណុលអាមេរិក បានធ្លាក់ចុះនៅក្បែរកម្រិតទាបនាពេលថ្មីៗនេះ ធៀបនឹងប្រាក់ដុល្លារអាមេរិក ខណៈដែលវិនិយោគិន បានរង់ចាំពិនិត្យមើលទិន្នន័យតម្លៃទំនិញអ្នកប្រើប្រាស់ (Consumer price data) សម្រាប់

ទិសដៅថ្មី។ វិនិយោគិនជាច្រើនបានរំពឹងថា ធនាគារកណ្តាលសហរដ្ឋអាមេរិក នឹងបង្ហាញផែនការកាត់បន្ថយការទិញប័ណ្ណបំណុលរបស់ខ្លួននៅចុងឆ្នាំនេះ ហើយការកាត់បន្ថយពិតប្រាកដ នឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយ។ *ដោយ សេន ចន្ទី*

*ប្រភព៖ Reuter.com ចេញផ្សាយថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១*

## រដ្ឋមន្ត្រីរតនាគារសហរដ្ឋអាមេរិក មានប្រសាសន៍ថា អត្រាការប្រាក់ខ្ពស់ អាចនឹងផ្តល់ផលល្អសម្រាប់សហរដ្ឋអាមេរិក




*ប្រភព៖ bloomberg, 2021*

យោងតាមប្រសាសន៍របស់លោកស្រី Janet Yellen រដ្ឋមន្ត្រីរតនាគារសហរដ្ឋអាមេរិក លោកប្រធានាធិបតី Joe Biden គួរតែជំរុញទៅមុខនូវផែនការចំណាយចំនួន ៤ ទ្រីលានដុល្លារអាមេរិក បើទោះបីជាកញ្ចប់ថវិកានេះនឹងធ្វើឱ្យអតិផរណាកើនឡើងនៅឆ្នាំក្រោយ និង អត្រាការប្រាក់កើនឡើងក៏ដោយ។

លោកស្រី Yellen បានមានប្រសាសន៍ទៀតថា កញ្ចប់ជំនួយរបស់លោកប្រធានាធិបតី Biden នឹងបន្ថែមចំណាយប្រហែល ៤០០ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ហើយលោកស្រីអះអាងថា ថវិកានេះមិនគ្រប់គ្រាន់ទេ ដែលធ្វើឱ្យមានអតិផរណាកើនហួសកម្រិត។

លោកស្រីបន្តថា តម្លៃទំនិញណាមួយដែលអាចកើនឡើងដោយសារកញ្ចប់សង្គ្រោះនោះនឹងបាត់ទៅវិញនៅឆ្នាំក្រោយ។

លោកស្រីបានបន្ថែមទៀតថា ប្រសិនបើយើងទទួលបានស្ថានភាពអត្រាការប្រាក់ខ្ពស់បន្តិច វាគឺជារឿងល្អសម្រាប់ទស្សនៈរបស់សង្គម និងធនាគារកណ្តាល។ ទន្ទឹមនឹងនេះដែរ លោកស្រីបានបញ្ជាក់ថា យើងបាននិងកំពុងប្រយុទ្ធប្រឆាំងនឹងអត្រាអតិផរណាទាប និង អត្រាការប្រាក់ទាបអស់រយៈពេលមួយទសវត្សរ៍មកហើយ។

តម្លៃទំនិញ (consumer prices) ជាគោល បានកើនឡើង ៤,២% ក្នុងរយៈពេល ១២ ខែ គិតត្រឹមខែមេសា ឆ្នាំ២០២១ ហើយតួលេខសម្រាប់ខែឧសភា គ្រោងនឹងចេញផ្សាយនៅថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ។

ធនាគារកណ្តាលសហរដ្ឋអាមេរិក បានប្តេជ្ញាថានឹងចាប់ផ្តើមកាត់បន្ថយការទិញទ្រព្យសកម្មរបស់ខ្លួនក្នុងមួយខែចំនួន ១២០ពាន់លានដុល្លារអាមេរិក បន្ទាប់ពីមានការកើនឡើងគួរឱ្យកត់សម្គាល់លើអតិផរណា និង អត្រាការងារ។ លោក Jerome Powell ប្រធានធនាគារកណ្តាល ដែលបានបន្តកាន់តំណែងពីលោកស្រី Yellen ក្នុងឆ្នាំ២០១៨ បានព្យាយាមបញ្ចុះបញ្ចូលវិនិយោគិនថាគាត់មិនពិចារណាក្នុងការដកថយការគាំទ្រដល់សេដ្ឋកិច្ចក្នុងពេលឆាប់ៗនេះទេ។ លោក Powell និងសហសេវិករបស់គាត់ បានបន្តព្យាករណ៍ការកំណត់អត្រាការប្រាក់សំខាន់ៗ ឱ្យខិតជិតសូន្យភាគរយ រហូតដល់ឆ្នាំ២០២៣។ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នៃក្រុមប្រទេស G7 និងធនាគារកណ្តាល បានចោទសួរលោកស្រី Yellen អំពីទស្សនៈរបស់លោកស្រី ចំពោះបញ្ហាអតិផរណា ហើយលោកស្រីបានមានប្រសាសន៍ថា អ្នកបង្កើតគោលនយោបាយរូបិយវត្ថុអាចដោះស្រាយនូវការកើនឡើងអតិផរណាដែលអាចកើតមាន។ *ដោយ សេន ចន្ទី*

*ប្រភព៖ Bloomberg.com ចេញផ្សាយថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១*

## កំណើនអតិផរណារបស់រុស្ស៊ី អាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច (ធនាគារកណ្តាលព្រមាន)




Russian Finance Minister Anton Siluanov and Central Bank Governor Elvira Nabiullina at the St. Petersburg International Economic Forum (SPIEF).

*ប្រភព៖ The MoscowTimes, 2021 រូបភាព៖ Anton Novoderezhkin/TASS*

ការកើនឡើងអតិផរណា បង្កការគំរាមកំហែងដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសរុស្ស៊ី។ អគ្គទេសាភិបាលធនាគារកណ្តាល លោកស្រី Elvira Nabiullina បានប្រាប់នៅវេទិកាសេដ្ឋកិច្ចអន្តរជាតិ St. Petersburg International Economic Forum (SPIEF) ថា "ដំបូង ការកើនឡើងអតិផរណាហាក់ដូចជារឿងបណ្តោះអាសន្ន ប៉ុន្តែបច្ចុប្បន្ន មិនដូចយើងគិតឡើយ"។

បច្ចុប្បន្ន អតិផរណារបស់ប្រទេសរុស្ស៊ី កំពុងមានអត្រា ៥,៥% ខ្ពស់ជាងអត្រាគោលដៅរបស់ធនាគារកណ្តាល ដែលបានកំណត់ត្រឹម ៤%។ ការឡើងថ្លៃទំនិញជាប្រចាំ គឺជាការព្រួយបារម្ភរបស់សាធារណៈជន ខណៈដែលសាធារណៈជនជឿជាក់ថា តម្លៃទំនិញកំពុងកើនឡើងលឿនជាងនេះជិត៣ដង ពោលគឺ អតិផរណាតាមការអង្កេត អាចនឹងមានអត្រាជិត១៥% នៅក្នុងខែឧសភា។ ធនាគារកណ្តាលបានលើកឡើងថា អតិផរណានឹងបន្តកើនឡើងពេញមួយឆ្នាំរហូតដល់ប្រមាណ ៥,៧៥% ត្រឹមខែធ្នូ ឆ្នាំ២០២១។ ប៉ុន្តែតម្លៃទីផ្សារកំពុងមានការកើនឡើងខ្លាំង ដែលពាណិជ្ជកររំពឹងថាអត្រាអតិផរណាអាចនឹងឈានដល់ជិត៦,៥% ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ The Moscow Times ចេញផ្សាយថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

### ថ្ងៃចន្ទ ទី១៤ ខែមិថុនា ឆ្នាំ២០២១

- កំណើនផលិតកម្មឧស្សាហកម្មរបស់ជប៉ុន ពីមួយខែទៅមួយខែ ក្នុងខែមេសា ឆ្នាំ ២០២១
- ការធ្លាក់ចុះសេដ្ឋកិច្ចអារ៉ាប៊ីសាអូឌីត នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២១
- ការថយចុះនៃការលក់យានយន្តសរុបនៅក្នុងប្រទេសឥណ្ឌាក្នុងខែមេសា ឆ្នាំ ២០២១

### ថ្ងៃអង្គារ ទី១៥ ខែមិថុនា ឆ្នាំ២០២១

- កំណើនការនាំចូល ទៅកាន់ប្រទេសឥណ្ឌូនេស៊ី ក្នុងខែមេសាឆ្នាំ ២០២១
- អត្រាអតិផរណាតម្លៃអ្នកប្រើប្រាស់នៅប្រទេសអាឡឺម៉ង់ ក្នុងខែឧសភាឆ្នាំ ២០២១

### ថ្ងៃពុធ ទី១៦ ខែមិថុនា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសជប៉ុន ក្នុងខែមេសាឆ្នាំ ២០២១
- កំណើនផលិតកម្មឧស្សាហកម្មរបស់ចិន ក្នុងខែមេសាឆ្នាំ ២០២១
- កំណើនអត្រាអតិផរណាប្រចាំឆ្នាំនៅចក្រភពអង់គ្លេស

### ថ្ងៃព្រហស្បតិ៍ ទី១៧ ខែមិថុនា ឆ្នាំ២០២១

- កំណើនអត្រាអតិផរណានៅប្រទេសអាហ្សង់ទីន នៅក្នុងខែមេសា ឆ្នាំ ២០២១
- ធនាគារកណ្តាលប្រេស៊ីលបានប្រកាសដំឡើងអត្រាការប្រាក់លើកទី២ របស់ខ្លួននៅក្នុងឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១៨ ខែមិថុនា ឆ្នាំ២០២១

- ការលក់រាយនៅចក្រភពអង់គ្លេស បានកើនឡើង ក្នុងខែមេសាឆ្នាំ ២០២១
- កំណើន អតិរេកគណនីចរន្តនៅតំបន់ចាយប្រាក់អឺរ៉ូ នៅខែមីនាឆ្នាំ ២០២១។